១–លោកជំទាវ ស៊ីង ឡូចលាង អនុរដ្ឋលេខាធិការ ជាប្រធាន

២–លោក ខឹម សោភ័ណ នាយក នាយកដ្ឋានផែនការ សមាជិក

៣–លោក ឈឿង ហេង នាយក នាយកដ្ឋានហិរញ្ញកិច្ច សមាជិក

៤–លោក យស សាខន ប្រធានអង្គភាពលទ្ធកម្ម លេខាធិការ

***គណៈកម្មាធិការនេះមានតួនាទី :***

–ទទួលខុសត្រូវការកំណត់ បុរេលក្ខណៈសម្បត្តិការដេញថ្លៃ ការវាយតំលៃលើ សំណើដេញថ្លៃ និង សំណើទីប្រឹក្សា ព្រមទាំងផ្តល់អនុសាសន៍ប្រគល់កិច្ចសន្យា ។

**ប្រការ៧ :** សេចក្តីប្រកាស សំរេចលេខ ១០២៣ រកន ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៥ ត្រូវបានចាត់ទុកជានិរាករណ៍ ។

**ប្រការ៨ :** សមាសភាពដែលបានចែងក្នុងប្រការ (៣)–(៤)–(៥)–(៦) ត្រូវអនុវត្តតាមសេចក្តីប្រកាស នេះអោយមានប្រសិទ្ធភាពចាប់ពី ថ្ងៃទីហត្ថលេខានេះតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គៀត សុគន្ធ**

* * *

## ៥–ទីស្តីការក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៦

### សារាចរណែនាំលេខ ០២ សក

### ស្តីពីការបើកប្រាក់ឧបត្ថម្ភមួយលើកជូនជនពិការ វិលទៅមូលដ្ឋាន និង ជនពិការស្លាប់ដោយរបួសចម្បាំង

ដើម្បីអនុវត្តសេចក្តីសំរេចលេខ ២០ សសរ ចុះថ្ងៃទី ៣០–០១–១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយចំពោះជនពលីពិការ និង សេចក្តីណែនាំអន្តរក្រសួងលេខ ០៩ សណន. ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩១ ស្តីពីការអនុវត្តន៍សេចក្តីសំរេចលេខ ២០

សសរ ចុះថ្ងៃទី ៣០-០១-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីអោយបានល្អ និង ច្បាស់លាស់ ជៀសវាងការភ័ន្តច្រឡំ ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន សូមធ្វើការណែនាំគ្រប់អធិការដ្ឋានសង្គមកិច្ចការងារ និង អតីតយុទ្ធជនខេត្ត-ក្រុងនូវខ្លឹមសារមួយចំនួនដូចតទៅ ÷

១-ការបើកប្រាក់ឧត្ថម្ភមួយលើកជូនជនពិការ វិលទៅរស់នៅមូលដ្ឋានតាម កំណត់ដូចមានចែងក្នុង កថាខ័ណ្ឌ" ឃ" ក្នុងចំណុច ១៣ ប្រការ ៧ នៃសេចក្ដីសំរេចលេខ ២០ សសរ ចុះថ្ងៃទី ៣០-០១-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្ដីពីរបបគោលនយោបាយចំពោះជនពលីពិការ គឺអនុវត្តចំពោះតែជនពិការដែលចេញពីមណ្ឌលចិញ្ចឹមក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនតែប៉ុណ្ណោះ ។ បច្ចុប្បន្នមណ្ឌលទាំងនេះបានប្រែក្លាយទៅជាមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈជនពិការ ឬ មណ្ឌលស្ដារលទ្ធភាពពលកម្ម ជនពិការហើយ ដូច្នេះការឧបត្ថម្ភតាមចំណុចខាងលើនេះមិនមានទៀតទេ ។

២-ករណីជនពិការដែលទទួលមរណៈភាពដោយរបួសសើរើ ហើយស្នើក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជនទទួលស្គាល់ជាជនពលី និង ផ្ដល់របបគោលនយោបាយជូនគ្រួសារត្រូវមានសំណុំលិខិតដូចចែង ក្នុងចំណុច" ក" និង" ខ" ខាងក្រោមនេះ ÷

ក-ករណីមរណៈភាពនៅមន្ទីរពេទ្យ ត្រូវមានលិខិតបញ្ជាក់ពីប្រធានមន្ទីរពេទ្យខេត្ត-ក្រុងដែលធានាអះ អាងថាពិតជាមរណៈភាពដោយរបួសសើរើប្រាកដមែន ។

ខ-ករណីមរណៈភាពនៅផ្ទះ ត្រូវមានលិខិតបញ្ជាក់ទទួលស្គាល់ពីគណៈកម្មការកោសល្យវិច្ច័យវេជ្ជសាស្ត្ររបស់សុខាភិបាលខេត្ត-ក្រុង ។

៣-ចំពោះរបបគោលនយោបាយសំរាប់ជនពិការប្រភេទ" ក" ដែលស្លាប់ដោយរបួសសើរើពិតប្រាកដ ហើយត្រូវផ្ទេរមកទទួលរបបពលីវិញ តាមចំណុចទី ៥ ប្រការ ៧ នៃសេចក្ដីសំរេចលេខ ២០ សសរ ចុះ ថ្ងៃទី ៣០-០១-១៩៩១ នោះគឺអនុវត្តតាមចំណុច II នៃប្រការ ២ របស់សេចក្ដីសំរេចលេខ ២០ សសរនេះ ។

អាស្រ័យហេតុនេះ សូមគ្រប់អធិការដ្ឋានសង្គមកិច្ច ការងារ និង អតីតយុទ្ធជនខេត្ត-ក្រុងអនុវត្តអោយបានត្រឹមត្រូវតាមខ្លឹមសារសារាចរណែនាំនេះ ។

ហត្ថលេខា និង ត្រា

**ស៊ុយ សែម**

* * *